ព្រឹទ្ធសភា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់ព្រឹទ្ធសភាប្រចាំខែឧសភា ឆ្នាំ២០២២

នៅក្នុងខែឧសភា ឆ្នាំ២០២២នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចដូចតទៅ៖

## ១-សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា

**១.១ សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា**

ក-សកម្មភាពចូលរួមកិច្ចប្រជុំ

-បានអញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ចំនួន៣លើក និងសម័យប្រជុំពេញអង្គ និងប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៤ ចំនួន២លើក។

**ខ-បដិសណ្ឋារកិច្ចជាមួយភ្ញៀវជាតិ-អន្តរជាតិ**

-បានអនុញ្ញាតឱ្យឯកឧត្តម Ivan vellmir Stacevi ឯកអគ្គរដ្ឋទូតតែងតាំងថ្មី នៃសាធារណរដ្ឋក្រូអាត ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម និងសវនាការ

-បានអនុញ្ញាតឱ្យគណៈប្រតិភូអន្តរសភាមិត្តភាពបារាំង-កម្ពុជា ដឹកនាំដោយឯកឧត្តម Vincent EBLÉ ចូលជួបសម្តែងការគួរសម និងសវនាការ

-បានអនុញ្ញាតឱ្យឯកឧត្តម Zaheeruddin Babar Thaheem ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋអ៊ីស្លាម ប៉ាគីស្ថាន ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម។

**គ-សកម្មភាពចុះមូលដ្ឋាន៖**

-បានអញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខមន្ត្រី អាជ្ញាធរ និងកងកម្លាំងនគរបាលប៉ុស្តិ៍ ក្នុងសង្កាត់អូរឬស្សីទី២ ខណ្ឌ៧មករា រាជធានីភ្នំពេញ។

**ឃ-សកម្មភាពចូលរួមពិធីផ្សេងៗ**

-បានអញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភាគោរពវិញ្ញាណក្ខន្ធ និងពិធីបញ្ចុះសពសម្តេចឧត្តមទេពញ្ញាណ **ហ៊ុន ណេង** សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ ប្រធានគណៈកម្មការមហាផ្ទៃ ការពារជាតិ និងមុខងារសាធារណៈ នៃរដ្ឋសភា និងជាតំណាងរាស្ត្រមណ្ឌល

កំពង់ចាម នៅវត្តសុវណ្ណគិរីរតនៈភ្នំប្រុស ខេត្តកំពង់ចាម

-បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីបុណ្យវិសាខបូជា នៅឧបដ្ឋានសាលា ខាងកើតព្រះមហាសក្យមុនីចេតិយ ភ្នំព្រះរាជទ្រព្យ (ឧត្តុង្គ) នៅស្រុកពញាឮ ខេត្តកណ្តាល។

**ង-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ**

-បានចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន១៦ច្បាប់ ផ្តល់យោបល់ចំនួន៣២ច្បាប់ និងជ្រាបជាព័ត៌មានចំនួន១២ច្បាប់។

**១.២ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ស៊ុម ចា អនុប្រធានទី១ ព្រឹទ្ធសភា**

**ក-សកម្មភាពចូលរួមកិច្ចប្រជុំ**

-បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ចំនួន៣លើក និងសម័យប្រជុំពេញអង្គ និងប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៤ ចំនួន២លើក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា។

**ខ-សកម្មភាពចុះមូលដ្ឋាន**

-បានអញ្ជើញចុះជួបពិភាក្សាការងារជាមួយមន្ត្រីជាថ្នាក់ដឹកនាំខេត្ត អំពីបញ្ហាដីនៅតំបន់អភិរក្សជាអតីតតំបន់តស៊ូ នៅឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង។

**គ-សកម្មភាពចូលរួមពិធីផ្សេងៗ**

-បានអញ្ជើញជាអធិបតីក្នុងពិធីរំលឹកទិវាជាតិនៃការចងចាំថ្ងៃទី២០ ឧសភា នៅភូមិរលួស សង្កាត់ជើងឯក ខណ្ឌដង្កោ រាជធានីភ្នំពេញ ដើម្បីរំលឹក និងចងចាំមិនអាចបំភ្លេចបាន ចំពោះអំពើឃោរឃៅប្រល័យពូជសាសន៍ ដែលបានធ្វើទារុណកម្ម និងកាប់សម្លាប់ប្រជាពលរដ្ឋខ្មែរក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ឬហៅថារបបប្រល័យពូជសាសន៍ ប៉ុល ពត។

**ឃ-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ**

-បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៩ច្បាប់ និងជ្រាបជាព័ត៌មានចំនួន៣៨ច្បាប់។

**១.៣ ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា**

**ក-សកម្មភាពចូលរួមកិច្ចប្រជុំ**

-បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ចំនួន៣លើក និងសម័យប្រជុំពេញអង្គ និងប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៤ ចំនួន២លើក ក្រោមអធិបតី-

ភាពដ៏ខ្ពង់ខ្ពស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា។

**ខ-សកម្មភាពចុះមូលដ្ឋាន**

-បានអញ្ជើញជាអធិបតីក្នុងពិធីសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ-សង្កាត់ទូទាំងខេត្តកណ្តាល ចំនួន១១លើក។

**គ-សកម្មភាពចូលរួមពិធីផ្សេងៗ**

-បានអញ្ជើញចូលរួមក្នុងពិធីបុណ្យសព និងពិធីបញ្ចុះសពសម្តេចឧត្តមទេពញ្ញាណ **ហ៊ុន ណេង** សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ ប្រធានគណៈកម្មការមហាផ្ទៃ ការពារជាតិ និងមុខងារសាធារណៈ នៃរដ្ឋសភា និងជាតំណាងរាស្ត្រមណ្ឌលកំពង់ចាម នៅវត្តសុវណ្ណគិរីរតនៈភ្នំប្រុស ខេត្តកំពង់ចាម និងដឹកនាំគណៈប្រតិភូព្រឹទ្ធសភាគោរពវិញ្ញាណក្ខន្ធសពឯកឧត្តមសន្តិបណ្ឌិត **ឌុល គឿន** តំណាងរាស្ត្រមណ្ឌលខេត្តកណ្តាល នៅគេហដ្ឋានសព ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ

-បានអញ្ជើញពិសារអាហារពេលល្ងាចជាមួយក្រុមសមាជិកាព្រឹទ្ធសភា នៅក្រុងតាខ្មៅ ខេត្តកណ្តាល។

**ឃ-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ**

-បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន១២ច្បាប់ និងជ្រាបជាព័ត៌មានចំនួន១០ច្បាប់។

## ២.សម័យប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

ព្រឹទ្ធសភាបានបើកកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន៣លើក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា ដើម្បីពិនិត្យសំណើរបស់រដ្ឋសភា និងគណៈកម្មការជំនាញព្រឹទ្ធសភា លើរបៀបវារៈដូចខាងក្រោម៖

១-ពិនិត្យ និងសម្រេចលើបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសតាំងជាសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមចំនួន១រូប ជំនួសសមាជិកដែលបានទទួលមរណភាព

២-ពិនិត្យ និងសម្រេចលើសេចក្តីព្រាងច្បាប់ ស្តីពីវិសោធនកម្មមាត្រា១៩០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨

៣-ពិនិត្យ និងសម្រេចលើសេចក្តីព្រាងច្បាប់ ស្តីពីសុវត្ថិភាពម្ហូបអាហារ ។

## ៣.សម័យប្រជុំពេញអង្គ និងប្រជុំវិសាមញ្ញ ព្រឹទ្ធសភា

ព្រឹទ្ធសភាបានបើកសម័យប្រជុំពេញអង្គ និងប្រជុំព្រឹទ្ធសភាជាវិសាមញ្ញចំនួន២លើក

ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា ដោយមានរបៀបវារៈដូចខាងក្រោម៖

១-ការបោះឆ្នោតជ្រើសតាំងសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ចំនួន១រូប ជំនួសសមាជិកដែលបានទទួលមរណភាព

២-ពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨

៣-ពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ ស្តីពីសុវត្ថិភាពម្ហូបអាហារ។

## ៤.គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា

សមាជិកព្រឹទ្ធសភា បានបំពេញការងារតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម៖

### ៤.១ មុខងារនីតិកម្ម

-បានអញ្ជើញចូលរួមកិច្ចប្រជុំជាមួយតំណាងរាជរដ្ឋាភិបាលដឹកនាំដោយឯកឧត្តម **អង្គ វង្ស វឌ្ឍានា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ដើម្បីពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់ស្តីពីសុវត្ថិភាពម្ហូបអាហារ និងសេចក្តីព្រាងច្បាប់ ស្តីពីវិសោធនកម្មមាត្រា១៨០ នៃច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ នៅសាលប្រជុំពិសេសព្រឹទ្ធសភា។

### ៤.២ មុខងារតាមដានការអនុវត្តច្បាប់

-បានអញ្ជើញប្រជុំពិភាក្សាការងារជាមួយគណៈអភិបាលខេត្ត ក្រុមប្រឹក្សាក្រុង កងកម្លាំងប្រដាប់អាវុធទាំងបីប្រភេទ ប្រធានអង្គភាពនានា និងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ និងមន្ត្រីរដ្ឋបាលក្រុង នៅខេត្តកំពង់ធំ និងខេត្តស្ទឹងត្រែង

-បានអញ្ជើញប្រជុំពិភាក្សាការងារជាមួយសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ ស្មៀន នាយប៉ុស្តិ៍នគរបាល និងមេភូមិ ដើម្បីឈ្វេងយល់ និងប្រមូលព័ត៌មានពាក់ព័ន្ធនឹងការអនុវត្តការងារ និងបញ្ហាប្រឈមនានា ដែលបានជួបប្រទះក្នុងការអនុវត្តការងារនាពេលកន្លងមក ព្រមទាំងបានក្រើនរំលឹកដល់ក្រុមប្រឹក្សាឃុំ សង្កាត់ឱ្យត្រៀមខ្លួនសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ នាពេលខាងមុខនេះ នៅខេត្តក្រចេះ ខេត្តស្ទឹងត្រែង និងខេត្តរតនគិរី

-បានអញ្ជើញប្រជុំពិភាក្សាការងារជាមួយសមាជិកក្រុមប្រឹក្សាឃុំ នៅខេត្តក្រចេះ និងខេត្តបាត់ដំបង។

### ៤.៣ មុខងារតំណាង

-បានអញ្ជើញចូលរួមកិច្ចប្រជុំពិនិត្យឯកសារសេចក្តីពន្យល់អំពីក្រមសីលធម៌សភារបស់សមាជិកព្រឹទ្ធសភា និងការត្រៀមចុះបេសកកម្មរបស់គណៈកម្មការនៅចន្លោះសម័យប្រជុំលើកទី៨ និងលើកទី៩ ព្រឹទ្ធសភា នីតិកាលទី៤ និងបញ្ហាផ្សេងៗ នៅសាលប្រជុំគណៈកម្មការទី២ វិមានព្រឹទ្ធសភា

-បានអញ្ជើញជាអធិបតីក្នុងពិធីបណ្តុះបណ្តាលអ្នកសង្កេតការណ៍របស់គណៈកម្មការសាខាសមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ រាជធានីភ្នំពេញ ដើម្បីប្រសិទ្ធភាពនៃការចូលរួមសង្កេតមើលដំណើរប្រព្រឹត្តទៅនៃការបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៥

-បានអញ្ជើញចូលរួមក្នុងវេទិកាជាតិស្ត្រីក្នុងភាពជាអ្នកដឹកនាំ និងអភិបាលកិច្ចរៀបចំឡើងដោយក្រសួងកិច្ចការនារី សហការរៀបចំ និងគាំទ្រពីក្រុមប្រឹក្សាវប្បធម៌អាស៊ី (ACC) ក្រោមអធិបតីភាពលោកជំទាវ កិត្តិសង្គហបណ្ឌិត **ឃួន សុដារី** អនុប្រធានទី២ រដ្ឋសភា និងជាប្រធានក្រុមសភាជាតិកម្ពុជា នៃអ្នកនយោបាយស្ត្រី នៅសណ្ឋាគាររ៉េស៊ីដង់សុខាភ្នំពេញ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ

-បានអញ្ជើញដឹកនាំកិច្ចប្រជុំពិនិត្យលើឯកសារ ត្រៀមផ្តល់កិច្ចសម្ភាសន៍ជូនសារព័ត៌មានវីអូឌី (VOD) នៃមជ្ឈមណ្ឌលកម្ពុជា ដើម្បីផ្សព្វផ្សាយ

-បានអញ្ជើញចូលរួមក្នុងពិធីសំណេះសំណាលជាមួយអនុសាខាសមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ ខណ្ឌចំការមន និងខណ្ឌបឹងកេងកង ដែលបានចូលរួមជាភ្នាក់ងារសង្កេតការណ៍ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៥ នាថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២២

-បានអនុញ្ញាតឱ្យក្រុមការងាររាជបណ្ឌិត្យសភាកម្ពុជា ដឹកនាំដោយឯកឧត្តមបណ្ឌិត **យង់ ពៅ** អគ្គលេខាធិការ ចូលជួបសម្តែងការគួរសម និងសម្ភាសន៍ ដើម្បីរៀបចំធ្វើគុណកថាក្នុងឱកាសដែលទទួលបានគោរមងារកិត្តិយសនៃរាជបណ្ឌិត្យសភាកម្ពុជា ជា « កិត្តិសេដ្ឋាបណ្ឌិត » នៅសាលប្រជុំគណៈកម្មការទី២ ព្រឹទ្ធសភា

-បានទទួលពាក្យបណ្តឹងចំនួន៩ករណី បញ្ជូនពាក្យបណ្តឹងទៅក្រសួង រាជធានី ខេត្ត និងស្ថាប័នពាក់ព័ន្ធចំនួន២ករណី កំពុងពិនិត្យសិក្សាចំនួន៥ករណី ធ្វើកំណត់បង្ហាញពាក្យ

បណ្តឹងចំនួន៩ករណី ឆ្លើយតបទៅម្ចាស់បណ្តឹងចំនួន២ករណី តម្កល់ទុកជាឯកសារចំនួន ១ករណី (សម្របសម្រួលដោះស្រាយបញ្ចប់) ព្រមទាំងទទួលឯកសារជូនជ្រាបពីក្រសួង ស្ថាប័នពាក់ព័ន្ធចម្លងជូនគណៈកម្មការចំនួន១៣ករណី

-សមាជិក សមាជិកាព្រឹទ្ធសភាបានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីបុណ្យវិសាខបូជាក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៅបរិវេណឧបដ្ឋានសាលាមុខព្រះមហាសក្យមុនីចេតិយ ភ្នំព្រះរាជទ្រព្យ (ឧត្តុង្គ) ស្រុកពញាឮ ខេត្តកណ្តាល

-បានអញ្ជើញជាគណៈអធិបតី និងចូលរួមជាកិត្តិយសក្នុងពិធីផ្លូវការផ្សេងៗចំនួន ១០៦លើក

-ដោយឡែក សមាជិក សមាជិកាព្រឹទ្ធសភាបានអញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ ក្រុមគ្រូពេទ្យ អតីតមន្ត្រីរាជការជានិវត្តជន អតីតយុទ្ធជន ក្រុមប្រឹក្សាឃុំ សង្កាត់ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពការងារ ការងារសន្តិសុខសណ្តាប់ធ្នាប់ ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ពិនិត្យហេដ្ឋារចនាសម្ព័ន្ធ និងសម្ពោធសមិទ្ធផលនានា ដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា ផ្សព្វផ្សាយអំពីវិធានការសុខាភិបាល ស្តីពីវិធីការពារខ្លួនពីជំងឺរាតត្បាតកូវីដ-១៩ ជាពិសេសអំពាវនាវឱ្យប្រជាពលរដ្ឋទៅចាក់វ៉ាក់សាំងទាំងដូសមូលដ្ឋាន និងដូសជំរុញឱ្យបានគ្រប់ៗគ្នា ចំនួន ២២០លើក នៅមូលដ្ឋានរាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តកំពង់ធំ ខេត្តតាកែវ ខេត្តកំពត ខេត្តកែប ខេត្តកំពង់ស្ពឺ ខេត្តត្បូងឃ្មុំ ខេត្តព្រៃវែង ខេត្តស្វាយរៀង ខេត្តព្រះសីហនុ ខេត្តសៀមរាប ខេត្តកំពង់ចាម ខេត្តបាត់ដំបង ខេត្តរតនគិរី ខេត្តបន្ទាយមានជ័យ ខេត្តឧត្តរមានជ័យ និងខេត្តស្ទឹងត្រែង។

### ៤.៤ កិច្ចសហប្រតិបត្តិការអន្តរជាតិ

សមាជិកព្រឹទ្ធសភា បានអញ្ជើញចូលរួមកិច្ចប្រជុំអន្តរជាតិនានា តាមប្រព័ន្ធវីដេអូ និងដោយផ្ទាល់ រួមមានៈ កិច្ចប្រជុំគណៈកម្មការនយោបាយនៃសភាប្រើភាសាបារាំង, កិច្ចប្រជុំគណៈកម្មការសភា(APF), កិច្ចប្រជុំក្រុមទទួលបន្ទុកការសើរើលក្ខន្តិកៈ (APF) , ជួបពិភាក្សាការងារជាមួយគណៈប្រតិភូអន្តរសភាមិត្តភាពបារាំង-កម្ពុជា, កិច្ចប្រជុំសភាតំបន់អាស៊ី (APA) ក្រោមប្រធានបទ " វេទិកាសភាស្តីពីការស្រាវជ្រាវ និងសហប្រតិបត្តិការកិច្ចការបណ្ណាល័យ ", កិច្ចប្រជុំដើម្បីត្រៀមរៀបចំកិច្ចប្រជុំប្រចាំឆ្នាំ AIPACODD លើកទី៥, និងសិក្ខា

សាលាស្តីពីពាណិជ្ជកម្មអន្តរជាតិ ឆ្នាំ២០២២ ដើម្បីផ្សព្វផ្សាយពាណិជ្ជកម្មជូនដល់សមាជិកសភាពិភពលោក ដោយមានការសហការរៀបចំជាមួយ Temasek Foundation និងអគ្គលេខាធិការដ្ឋាននៃអង្គការពាណិជ្ជកម្មពិភពលោក(WTO)។ ក្រៅពីចូលរួមកិច្ចប្រជុំ សមាជិកព្រឹទ្ធសភាក៏បានជួបពិភាក្សាការងារជាមួយគណៈប្រតិភូសាធារណរដ្ឋប្រជាមានិតចិន និងបានអញ្ជើញទៅទស្សនកិច្ចសិក្សាឈ្វេងយល់នៅតំបន់អភិវឌ្ឍន៍កសិកម្ម កសិឧស្សាហកម្មកែវផុស ចម្ការដូងប្រេង ចម្ការកៅស៊ូ ចម្ការឈើហូបផ្លែ រោងចក្រផលិតចំណីសត្វ កសិដ្ឋានចិញ្ចឹមជ្រូក រោងចក្រកែច្នៃស្បែក និងរោងចក្រស្លដែក។

ថ្ងៃព្រហស្បតិ៍ ៣កើត ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែមិថុនា ឆ្នាំ២០២២

ជ.ប្រធានព្រឹទ្ធសភា

អនុប្រធានទី២

កិត្តិសង្គហបណ្ឌិត ទេព ងន

ចម្លងជូន

- ក្រសួងព្រះបរមរាជវាំង
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងព័ត៌មាន
- (ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)
- កាលប្បវត្តិ-ឯកសារ